**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ៦៩០......សហវ.ប្រក

# ប្រកាស

## ស្តីពី

## វិធាននិងនីតិវិធីនៃការបង់ពន្ធលើប្រាក់ចំណូលសម្រាប់សហគ្រាសធានារ៉ាប់រង

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨១៤/០២១ ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធានារ៉ាប់រង
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៦/០១៩ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92,Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax: 855-23-427 798

## សម្រេច

**ប្រការ ១.- គោលបំណង**

ប្រកាសនេះ មានគោលបំណងធ្វើវិចារណកម្មពន្ធលើប្រាក់ចំណូលសម្រាប់សហគ្រាសធានារ៉ាប់រង ដើម្បីជំរុញនិងអភិវឌ្ឍវិស័យធានារ៉ាប់រងនៅព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២.- គោលដៅ**

ប្រកាសនេះ មានគោលដៅកំណត់អំពីវិធាននិងនីតិវិធីនៃការបង់ពន្ធលើប្រាក់ចំណូលសម្រាប់សហគ្រាសធានារ៉ាប់រង ស្របតាមមាត្រា ២១ ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ ដែលត្រូវបានធ្វើវិសោធនកម្មដោយមាត្រា១០ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧។

**ប្រការ ៣.- វិសាលភាព**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះសហគ្រាសធានារ៉ាប់រងដែលមាន÷

១- សកម្មភាពធានារ៉ាប់រងឬធានារ៉ាប់រងបន្តលើទ្រព្យសម្បត្តិឬហានិភ័យផ្សេងៗនៅព្រះរាជាណាចក្រកម្ពុជា

២- សកម្មភាពធានារ៉ាប់រងឬធានារ៉ាប់រងបន្តលើជីវិតដែលមានលក្ខណៈសន្សំ និងសកម្មភាពផ្សេងទៀតក្រៅពីធានារ៉ាប់រង ឬធានារ៉ាប់រងបន្តលើទ្រព្យសម្បត្តិ ឬហានិភ័យផ្សេងៗ ដូចមានកំណត់នៅក្នុងកថាខណ្ឌ ១ នៃប្រការនេះ។

**ប្រការ ៤.- និយមន័យ**

សម្រាប់គោលដៅនៃប្រកាសនេះ ÷

១- ពាក្យ "**ធានារ៉ាប់រង**" សំដៅដល់កិច្ចសន្យាធានារ៉ាប់រងដែលធ្វើឡើងរវាងសហគ្រាសធានារ៉ាប់រងនិងអ្នកត្រូវបានធានារ៉ាប់រង ដោយតម្រូវឱ្យអ្នកត្រូវបានធានារ៉ាប់រង បង់បុព្វលាភធានារ៉ាប់រងទៅឱ្យសហគ្រាសធានារ៉ាប់រង ហើយសហគ្រាសធានារ៉ាប់រងត្រូវធ្វើសំណងដល់ការខូចខាត ឬការបាត់បង់ទ្រព្យសម្បត្តិដែលបង្កឡើងដោយហេតុការណ៍គ្រោះថ្នាក់ ឬក៏ធ្វើសំណងនៅពេលដែលអ្នកត្រូវបានធានារ៉ាប់រងស្លាប់ របួស ពិការ មានជំងឺ ឬនៅពេលដែលបុគ្គលនោះឈានដល់កាលកំណត់ណាមួយដែលភាគីទាំងពីរបានព្រមព្រៀងគ្នាដូចមានចែងក្នុងកិច្ចសន្យាធានារ៉ាប់រង។

២- ពាក្យ "**ធានារ៉ាប់រងទូទៅ**" សំដៅដល់កិច្ចសន្យាធានារ៉ាប់រងដែលធ្វើឡើងរវាងអ្នកត្រូវបានធានារ៉ាប់រងនិងសហគ្រាសធានារ៉ាប់រង ដែលក្នុងនោះ ការបង់បុព្វលាភធានារ៉ាប់រងត្រូវធ្វើឡើងដើម្បីធានាហានិភ័យលើទ្រព្យសម្បត្តិ ភារៈទទួលខុសត្រូវ និងសុខភាព។ ប្រភេទផលិតផលធានារ៉ាប់រងទូទៅរួមមានការធានារ៉ាប់រងទ្រព្យសម្បត្តិ ការធានារ៉ាប់រងភារៈទទួលខុសត្រូវ និងការធានារ៉ាប់រងសុខភាព។

៣- ពាក្យ "**ធានារ៉ាប់រងលើជីវិត**" សំដៅដល់កិច្ចសន្យាធានារ៉ាប់រង ដែលធ្វើឡើងរវាងអ្នកត្រូវបានធានារ៉ាប់រង និងសហគ្រាសធានារ៉ាប់រង ដែលក្នុងនោះការបង់បុព្វលាភធានារ៉ាប់រងត្រូវធ្វើឡើងដើម្បីធានាទៅលើការស្លាប់ ឬការរស់រានមានជីវិត ដោយអាចរួមបញ្ចូលការធានារ៉ាប់រងលើគ្រោះថ្នាក់បុគ្គល ជំងឺធ្ងន់ធ្ងរ ឬជំងឺទូទៅ។ ប្រភេទផលិតផលធានារ៉ាប់រងលើជីវិតមាន ការធានារ៉ាប់រងមានកាលកំណត់ ការធានារ៉ាប់រងមួយជីវិតកាល ការធានារ៉ាប់រងទាយជ្ជទាន ការធានារ៉ាប់រងធនលាភ។ សម្រាប់

គោលដៅនៃប្រកាសនេះ សកម្មភាពធានារ៉ាប់រងនានា ដូចមានចែងក្នុងកថាខណ្ឌនេះ ត្រូវបានចាត់ទុកថាជាសកម្មភាពធានារ៉ាប់រងលើជីវិតដែលមានលក្ខណៈសន្សំ។

៤- ពាក្យ "**ធានារ៉ាប់រងបន្ត**" សំដៅដល់កិច្ចប្រតិបត្តិការធានារ៉ាប់រងដែលសហគ្រាសធានារ៉ាប់រងដើមត្រូវបានធានារ៉ាប់រងដោយសហគ្រាសធានារ៉ាប់រងផ្សេងទៀត ដើម្បីធានារ៉ាប់រងបន្តមួយផ្នែក ឬទាំងស្រុងនូវហានិភ័យដែលសហគ្រាសធានារ៉ាប់រងដើមបានចុះកិច្ចសន្យាធានារ៉ាប់រង។

៥- ពាក្យ "**ប័ណ្ណសន្យារ៉ាប់រង**" សំដៅដល់ឯកសារចងភ្ជាប់កាតព្វកិច្ចតាមផ្លូវច្បាប់ដែលចេញដោយសហគ្រាសធានារ៉ាប់រង ដោយមានកំណត់ខ្លឹមសារសំខាន់និងចែងពីលក្ខខណ្ឌលម្អិតដែលបានព្រមព្រៀងរវាងសហគ្រាសធានារ៉ាប់រងនិងអ្នកត្រូវបានធានារ៉ាប់រងនៅក្នុងកិច្ចសន្យាធានារ៉ាប់រង។

៦- ពាក្យ "**បុព្វលាភធានារ៉ាប់រង**" សំដៅដល់ចំនួនទឹកប្រាក់ដែលអ្នកត្រូវបានធានារ៉ាប់រងត្រូវបង់ទៅឱ្យសហគ្រាសធានារ៉ាប់រង តាមការកំណត់របស់សហគ្រាសធានារ៉ាប់រងនៅក្នុងប័ណ្ណសន្យារ៉ាប់រង ។

៧- ពាក្យ "**បុព្វលាភធានារ៉ាប់រងដុល**" សំដៅដល់ចំនួនទឹកប្រាក់ដែលបានបង់ដោយអ្នកត្រូវបានធានារ៉ាប់រង ទោះបីជាមានលក្ខណៈបង់ទាំងស្រុង ឬបង់រំលស់ទៅតាមដំណាក់កាលក៏ដោយ ដោយផ្អែកលើគោលការណ៍សាច់ប្រាក់។

៨- ពាក្យ "**បុព្វលាភធានារ៉ាប់រងបន្តដុល**" សំដៅដល់ចំនួនទឹកប្រាក់ដែលក្រុមហ៊ុនធានារ៉ាប់រងធ្វើធានារ៉ាប់រងបន្តទៅក្រុមហ៊ុនធានារ៉ាប់រងបន្ត។

៩- ពាក្យ "**សហគ្រាសធានារ៉ាប់រង**" សំដៅដល់ក្រុមហ៊ុនធានារ៉ាប់រងទូទៅ ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច និងក្រុមហ៊ុនធានារ៉ាប់រងបន្ត។

១០- ពាក្យ "**ចំណាយទូទាត់សំណងធានារ៉ាប់រង**" សំដៅដល់ចំណាយសម្រាប់ជាផលប្រយោជន៍របស់អ្នកត្រូវបានធានារ៉ាប់រង ឬអ្នកទទួលផលដែលសហគ្រាសធានារ៉ាប់រង ត្រូវសងតាមកាលកំណត់នៃកិច្ចសន្យាធានារ៉ាប់រង ចំណាយត្រូវសងលើតម្លៃនៃការបោះបង់កិច្ចសន្យាធានារ៉ាប់រង ចំណាយត្រូវសងលើសំណងធានារ៉ាប់រង និងចំណាយត្រូវសងលើភាគលាភពីការធានារ៉ាប់រងជីវិតរបស់អ្នកត្រូវបានធានារ៉ាប់រងឬអ្នកទទួលផល។

១១- ពាក្យ "**ភាគលាភពីការធានារ៉ាប់រងលើជីវិត**" សំដៅដល់ការប្រាក់ដែលអ្នកត្រូវបានធានារ៉ាប់រងឬអ្នកទទួលផល ទទួលបានបន្ថែមពីការទិញធានារ៉ាប់រងលើជីវិត ឬផលបន្ថែមដែលបានពីការវិនិយោគតាមការកំណត់ក្នុងកិច្ចសន្យាធានារ៉ាប់រង។

**ប្រការ ៥.- ពន្ធលើប្រាក់ចំណូលចំពោះក្រុមហ៊ុនធានារ៉ាប់រងទូទៅ ក្រុមហ៊ុនធានារ៉ាប់រងបន្តទូទៅ និងក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច**

ពន្ធលើប្រាក់ចំណូលចំពោះក្រុមហ៊ុនធានារ៉ាប់រងទូទៅ ក្រុមហ៊ុនធានារ៉ាប់រងបន្តទូទៅ និងក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច ត្រូវបានកំណត់ដូចតទៅ÷

១- សកម្មភាពធានារ៉ាប់រងទូទៅ ឬធានារ៉ាប់រងបន្តទូទៅ ឬធានារ៉ាប់រងខ្នាតតូច ត្រូវជាប់ពន្ធលើប្រាក់ចំណូលតាមអត្រា ៥ (ប្រាំ) ភាគរយ នៃបុព្វលាភធានារ៉ាប់រងដុលដែលទទួលបាននៅក្នុងឆ្នាំជាប់ពន្ធ។ ពន្ធលើប្រាក់ចំណូលនេះត្រូវប្រកាសនិងបង់ជូនរដ្ឋបាលសារពើពន្ធក្នុងអំឡុងពេល ២០ ថ្ងៃនៃខែបន្ទាប់ពីខែដែលទទួលបានបុព្វលាភធានារ៉ាប់រង។ បុព្វលាភធានារ៉ាប់រងដុល បុព្វលាភធានារ៉ាប់រងបន្តលើប័ណ្ណសន្យារ៉ាប់រង ដែលក្រុមហ៊ុន

ធានារ៉ាប់រងទូទៅ និងក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូចបានបង់ពន្ធលើប្រាក់ចំណូលតាមអត្រា ៥ ភាគរយរួចហើយ មិនត្រូវចាត់ទុកជាចំណូលជាប់ពន្ធរបស់ក្រុមហ៊ុនធានារ៉ាប់រងបន្តទូទៅទេ ដែលក្នុងករណីនេះក្រុមហ៊ុនធានារ៉ាប់រងបន្តទូទៅ ត្រូវទូទាត់ប្រាក់ពន្ធនៃបុព្វលាភធានារ៉ាប់រងបន្តដែលក្រុមហ៊ុនធានារ៉ាប់រងទូទៅនិងក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូចបានបង់ជំនួស។

២- ចំណូលការប្រាក់ដែលទទួលបានពីការតម្កល់ប្រាក់នៅធនាគារ ដែលត្រូវបានកាត់ទុកនិងបង់ពន្ធរួចហើយ តាមប្រការ ៩ នៃប្រកាសនេះ មិនត្រូវជាប់ពន្ធលើប្រាក់ចំណូលទៀតទេ។

៣- កម្រៃជើងសា និងសំណងធានារ៉ាប់រងត្រឡប់វិញ ដែលទទួលបានពីក្រុមហ៊ុនធានារ៉ាប់រងបន្តទូទៅ និងក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូចមិនត្រូវជាប់ពន្ធលើប្រាក់ចំណូលតាមមាត្រា២០ថ្មី(មួយ)នៃច្បាប់ស្តីពីសារពើពន្ធទេ។

៤- ប្រាក់ចំណូលពីសកម្មភាពផងទៃទៀត ក្រៅពីចំណូលពីការធានារ៉ាប់រងទូទៅ ការធានារ៉ាប់រងបន្តទូទៅ ការធានារ៉ាប់រងខ្នាតតូច ចំណូលការប្រាក់ កម្រៃជើងសា និងសំណងធានារ៉ាប់រងត្រឡប់វិញ ដូចមានចែងក្នុងកថាខណ្ឌ ១ កថាខណ្ឌ ២ និងកថាខណ្ឌ ៣ នៃប្រការនេះ ត្រូវជាប់ពន្ធលើប្រាក់ចំណូលតាមអត្រាដូចមានចែងក្នុងមាត្រា២០ថ្មី(មួយ) និងមាត្រា២៨ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ ហើយអនុញ្ញាតឱ្យកាត់កងតែចំណាយទាំងឡាយណាដែលពាក់ព័ន្ធដោយផ្ទាល់នឹងប្រតិបត្តិការចំណូលពីសកម្មភាពផងទៃទៀតទាំងនោះតែប៉ុណ្ណោះ។

**ប្រការ ៦.- ពន្ធលើប្រាក់ចំណូលចំពោះក្រុមហ៊ុនធានារ៉ាប់រង ឬធានារ៉ាប់រងបន្តលើអាយុជីវិត**

ពន្ធលើប្រាក់ចំណូលចំពោះក្រុមហ៊ុនធានារ៉ាប់រងឬធានារ៉ាប់រងបន្តលើអាយុជីវិត ត្រូវបានកំណត់ដូចខាងក្រោម÷

១- ត្រូវជាប់ពន្ធលើប្រាក់ចំណូលតាមអត្រាដូចមានចែងក្នុងមាត្រា ២០ ថ្មី (មួយ) នៃច្បាប់ស្តីពីសារពើពន្ធចំពោះ÷

ក- ប្រាក់ចំណូលដែលទទួលបានពីសកម្មភាពធានារ៉ាប់រង ឬធានារ៉ាប់រងបន្តលើជីវិតដូចមានចែងក្នុងកថាខណ្ឌ ៣ នៃប្រការ ៤ រួមទាំងបុព្វលាភធានារ៉ាប់រងបន្ត កម្រៃជើងសាពីសកម្មភាពធានារ៉ាប់រងបន្ត និងសំណងធានារ៉ាប់រងត្រឡប់វិញ។

ខ- ចំណូលការប្រាក់ដែលទទួលបានពីការតម្កល់ប្រាក់នៅធនាគារ ដែលត្រូវបានកាត់ទុកនិងបង់ពន្ធរួចហើយតាមប្រការ៩ នៃប្រកាសនេះ ដោយអនុញ្ញាតឱ្យកាត់កងឥណទានពន្ធដែលធនាគារបានកាត់ទុករួច។

គ- ចំណូលពីការវិនិយោគ ថ្លៃឈ្នួល សួយសារ សំណងផ្សេងៗរួមទាំងប្រាក់ចំណូលពីទ្រព្យសកម្មហិរញ្ញវត្ថុ ឬទ្រព្យសកម្មវិនិយោគរាប់ទាំងអចលនទ្រព្យផង ចំណេញមូលធនដែលសម្រេចបានក្នុងពេលកំពុងប្រកបអាជីវកម្ម ឬនៅពេលបញ្ចប់អាជីវកម្ម ចំណេញមូលធនពីអចលនទ្រព្យ ទ្រព្យហិរញ្ញវត្ថុ ឬទ្រព្យវិនិយោគ ដែលទទួលបានក្រៅពីប្រតិបត្តិការអាជីវកម្ម។

ឃ- ប្រាក់ចំណូលផ្សេងៗទៀត ក្រៅពីប្រាក់ចំណូលដូចមានកំណត់ក្នុងវាក្យខណ្ឌ ក វាក្យខណ្ឌ ខ និងវាក្យខណ្ឌ គ នៃកថាខណ្ឌនេះ។

២- ត្រូវបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណូលចំពោះសកម្មភាពធានារ៉ាប់រងឬធានារ៉ាប់រងបន្តលើជីវិត និងសកម្មភាពផងទៃទៀត ក្រៅពីសកម្មភាពធានារ៉ាប់រងឬធានារ៉ាប់រងបន្តនូវការធានារ៉ាប់រងទូទៅ តាមអត្រា ១ ភាគរយនៃផលរបរដែលទទួលបានក្នុងខែ។ សម្រាប់គោលដៅនៃប្រការនេះ ពាក្យ "ផលរបរ" សំដៅដល់ ÷

ក- បុព្វលាភដុល និងចំណូលផ្សេងៗដែលទទួលបានពីសកម្មភាពធានារ៉ាប់រង ឬធានារ៉ាប់រងបន្តលើជីវិត វៀរលែងតែបុព្វលាភធានារ៉ាប់រងដុលដែលត្រូវបានលុបចោល និងសំណងធានារ៉ាប់រងត្រឡប់វិញ។

ខ- ចំណូលពីសកម្មភាពដទៃទៀត។

៣- ចំណាយនានា វៀរលែងតែប្រាក់បម្រុងបច្ចេកទេសដូចមានចែងក្នុងប្រការ ៧ នៃប្រកាសនេះ ត្រូវអនុវត្តតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារជាធរមាន។

**ប្រការ ៧.- ប្រាក់បម្រុងបច្ចេកទេសសម្រាប់សកម្មភាពក្រុមហ៊ុនធានារ៉ាប់រងឬធានារ៉ាប់រងបន្តលើអាយុជីវិត**

សម្រាប់គោលដៅនៃប្រកាសនេះ ប្រាក់បម្រុងបច្ចេកទេសសម្រាប់សកម្មភាពធានារ៉ាប់រងឬធានារ៉ាប់រងបន្តលើជីវិត សម្រាប់ឆ្នាំជាប់ពន្ធណាមួយ ត្រូវអនុវត្តដូចខាងក្រោម÷

១- នៅក្នុងឆ្នាំជាប់ពន្ធ សហគ្រាសធានារ៉ាប់រងត្រូវបានអនុញ្ញាតឱ្យធ្វើសំវិធានធននូវប្រាក់បម្រុងបច្ចេកទេសតាមចំនួនដែលសហគ្រាសបានគណនាតាមនិយាមអន្តរជាតិ ដែលមានការទទួលស្គាល់ពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ការកំណត់អំពីវិធាននិងនីតិវិធីសម្រាប់ការគណនាប្រាក់បម្រុងបច្ចេកទេសនឹងមានកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងរយៈពេលមិនលើសពី ០៣ឆ្នាំ ក្រោយការចេញប្រកាសនេះ។

២- ក្នុងករណីនៅឆ្នាំជាប់ពន្ធណាមួយ ប្រាក់បម្រុងបច្ចេកទេស ដូចមានចែងក្នុងកថាខណ្ឌ ១ នៃប្រការនេះ មានចំនួនតិចជាងទឹកប្រាក់ដែលមាននៅក្នុងគណនីប្រាក់បម្រុងបច្ចេកទេស ចំនួនលម្អៀងត្រូវកត់ត្រាជាចំណូលនៅក្នុងឆ្នាំជាប់ពន្ធនោះ។

៣- ក្នុងករណីនៅឆ្នាំជាប់ពន្ធណាមួយ ប្រាក់បម្រុងបច្ចេកទេស ដូចមានចែងក្នុងកថាខណ្ឌ ១ នៃប្រការនេះ មានចំនួនច្រើនជាងទឹកប្រាក់ដែលមាននៅក្នុងគណនីប្រាក់បម្រុងបច្ចេកទេស ចំនួនលម្អៀងត្រូវកត់ត្រាជាចំណាយនៅក្នុងឆ្នាំជាប់ពន្ធនោះ។

៤- ក្នុងករណីសំណងធានារ៉ាប់រងមិនត្រូវបានទូទាត់តាមកាលកំណត់នៃកិច្ចសន្យាធានារ៉ាប់រង ហើយគ្មានការស្នើសុំតវ៉ាពីអ្នកត្រូវបានធានារ៉ាប់រង ឬអ្នកទទួលផល ក្នុងរយៈពេល ០២ ឆ្នាំ ទឹកប្រាក់សំណងធានារ៉ាប់រងនេះត្រូវកត់ត្រាជាចំណូលក្នុងឆ្នាំជាប់ពន្ធ។

**ប្រការ ៨.- ពន្ធកាត់ទុក**

សហគ្រាសធានារ៉ាប់រង ត្រូវមានកាតព្វកិច្ចកាត់ទុកប្រាក់ពន្ធ ដូចមានចែងក្នុងមាត្រា ២៥ ថ្មី និងមាត្រា ២៦ថ្មី(មួយ) នៃច្បាប់ស្តីពីសារពើពន្ធ និងត្រូវដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធដែលបានកាត់ទុកក្នុងរយៈពេល ២០ ថ្ងៃនៃខែបន្ទាប់ពីខែដែលបានធ្វើការកាត់ទុក។

សហគ្រាសធានារ៉ាប់រងដែលធ្វើការទូទាត់ទៅឱ្យអ្នកជាប់ពន្ធអនិវាសនជន ដើម្បីធ្វើការធានារ៉ាប់រងបន្តនូវការធានារ៉ាប់រងទូទៅ ដូចមានកំណត់ក្នុងប្រការ៥ នៃប្រកាសនេះ ពុំមានកាតព្វកិច្ចបង់ពន្ធកាត់ទុកទេ។

សហគ្រាសធានារ៉ាប់រង ដែលធ្វើការទូទាត់ទៅឱ្យអ្នកជាប់ពន្ធអនិវាសនជន ដើម្បីធ្វើការធានារ៉ាប់រងបន្តនូវការធានារ៉ាប់រងលើជីវិត ត្រូវជាប់ពន្ធកាត់ទុកតាមមាត្រា ២៦ ថ្មី (មួយ) នៃច្បាប់ស្តីពីសារពើពន្ធ ចំពោះបុព្វលាភធានារ៉ាប់រងបន្តសុទ្ធ។ សម្រាប់គោលដៅនៃប្រកាសនេះ ពាក្យ "បុព្វលាភធានារ៉ាប់រងបន្តសុទ្ធ" សំដៅដល់បុព្វលាភធានារ៉ាប់រងបន្តដុលនៃការធានារ៉ាប់រងលើជីវិត ដកចំណាយសំណងត្រឡប់វិញ និងកម្រៃជើងសាពីការធានារ៉ាប់រងបន្ត។

សម្រាប់គោលដៅនៃពន្ធកាត់ទុក ចំណាយណាមួយដែលជាកម្មវត្ថុនៃពន្ធកាត់ទុក ដែលបានកត់ត្រាក្នុងបញ្ជីគណនេយ្យ ត្រូវចាត់ទុកថាបានទូទាត់។

**ប្រការ ៩.- ពន្ធនិងអាករដទៃទៀត**

ចំពោះពន្ធនិងអាករដទៃទៀត សហគ្រាសធានារ៉ាប់រងត្រូវបំពេញកាតព្វកិច្ចតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ ១០.- និរាករណ៍**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ ១១.- ការអនុវត្ត**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក និងអគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគ្រប់សហគ្រាសធានារ៉ាប់រង ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃច័ន្ទ ១ រោច ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០១៨

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី-ខេត្ត
- ដូចប្រការ ១១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ